ក្រសួងមុខងារសាធារណៈ
រដ្ឋបាល
ចូល
លេខ: ៤៩៣៣
មកដល់ថ្ងៃទី ០៧ ខែ ៩ ឆ្នាំ ១៨
ម៉ោង ៤:១៥ PM

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខៈ** ៧៤៤ អនក្រ.បក

# អនុក្រឹត្យ
## ស្ដីពី
## ប្រាក់បំណាច់មុខងារមន្ត្រីរាជការស៊ីវិលនៃក្រសួងអប់រំ យុវជន និងកីឡា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២០១/៤៥០ ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០០១ ស្តីពីបៀវត្សមូលដ្ឋាននិងប្រាក់បន្ទាប់បន្សំនៃបៀវត្សរបស់មន្ត្រីរាជការស៊ីវិល
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈនិងជាប្រធានគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ

## សម្រេច

**មាត្រា១ .-**

អនុក្រឹត្យនេះ មានគោលបំណងរៀបចំនិងកំណត់ប្រាក់បំណាច់មុខងាររបស់មន្ត្រីរាជការស៊ីវិលនៃក្រសួងអប់រំ យុវជន និងកីឡា ។

**មាត្រា២ .-**

អនុក្រឹត្យនេះ មានគោលដៅកំណត់ឱ្យមានការរួមបញ្ចូលតែមួយនូវប្រាក់បំណាច់មុខងារក្នុងវិស័យអប់រំ ប្រាក់គរុកោសល្យ ប្រាក់ហានិភ័យតំបន់ និងប្រាក់ហានិភ័យសុខភាពបច្ចុប្បន្នរបស់មន្ត្រីរាជការស៊ីវិលនៃក្រសួងអប់រំ យុវជន និងកីឡា ឱ្យទៅជាប្រាក់បំណាច់មុខងារអប់រំ និង ឱ្យមានការរួមបញ្ចូលតែមួយនូវប្រាក់បំណាច់មុខងាររដ្ឋបាលទូទៅ ប្រាក់គរុកោសល្យ ប្រាក់ហានិភ័យតំបន់ និងប្រាក់ហានិភ័យសុខភាពបច្ចុប្បន្នរបស់មន្ត្រីរាជការស៊ីវិលនៃក្រសួងអប់រំ យុវជន និងកីឡា ឱ្យទៅជាប្រាក់បំណាច់មុខងាររដ្ឋបាល។

**មាត្រា៣ ._**

អនុក្រឹត្យនេះ មានវិសាលភាពអនុវត្តចំពោះមន្ត្រីរាជការស៊ីវិលនិងមន្ត្រីកម្មសិក្សានៃក្រសួងអប់រំ យុវជន និងកីឡា។

**មាត្រា៤ ._**

ប្រាក់បំណាច់មុខងារអប់រំ ជាប្រាក់បំណាច់មុខងារប្រចាំខែដែលត្រូវផ្ដល់ជូនមន្ត្រីរាជការស៊ីវិលកំពុងបំពេញមុខងារក្នុងក្របខណ្ឌគ្រូបង្រៀនកម្រិតបឋម ក្របខណ្ឌគ្រូបង្រៀនកម្រិតមូលដ្ឋាន និងក្របខណ្ឌគ្រូបង្រៀនកម្រិតឧត្តមនៃក្រសួងអប់រំ យុវជន និងកីឡា ដូចមានកំណត់ក្នុងតារាងខាងក្រោម៖

| ល.រ | បរិយាយ | ប្រាក់បំណាច់មុខងារអប់រំ (រៀល) |
|---|---|---|
| ១ | គ្រូបង្រៀនកម្រិតបឋម | ១៥០ ០០០ |
| ២ | នាយករងសាលាបឋមសិក្សា | ១៧០ ០០០ |
| ៣ | នាយករងមត្តេយ្យសិក្សា | ១៧០ ០០០ |
| ៤ | នាយកសាលាបឋមសិក្សា | ១៨០ ០០០ |
| ៥ | នាយកសាលាមត្តេយ្យសិក្សា | ១៨០ ០០០ |
| ៦ | គ្រូបង្រៀនកម្រិតមូលដ្ឋាន | ១៨០ ០០០ |
| ៧ | អនុប្រធានការិយាល័យមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត | ១៨០ ០០០ |
| ៨ | អនុប្រធានការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក ខណ្ឌ | ១៨០ ០០០ |
| ៩ | នាយករងអនុវិទ្យាល័យ | ១៩០ ០០០ |
| ១០ | ប្រធានការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក ខណ្ឌ | ១៩០ ០០០ |
| ១១ | ប្រធានការិយាល័យមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត | ១៩០ ០០០ |
| ១២ | អនុប្រធានការិយាល័យថ្នាក់កណ្ដាលនៃក្រសួងអប់រំ យុវជន និង កីឡា | ១៩០ ០០០ |
| ១៣ | នាយកអនុវិទ្យាល័យ | ២០០ ០០០ |
| ១៤ | អនុប្រធានមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត | ២០០ ០០០ |
| ១៥ | ប្រធានការិយាល័យថ្នាក់កណ្ដាល | ២០០ ០០០ |
| ១៦ | អធិការបឋមសិក្សា | ២០០ ០០០ |
| ១៧ | គ្រូឧទ្ទេសបឋម (ក្របខណ្ឌគ្រូបង្រៀនកម្រិតបឋម) | ២០០ ០០០ |
| ១៨ | គ្រូឧទ្ទេសកម្រិតមូលដ្ឋាន (ក្របខណ្ឌគ្រូបង្រៀនកម្រិតមូលដ្ឋាន) | ២៣០ ០០០ |
| ១៩ | គ្រូបង្រៀនកម្រិតឧត្តម(បង្រៀននៅមធ្យមសិក្សាទុតិយភូមិ) | ២៦០ ០០០ |
| ២០ | នាយករងសាលាគរុកោសល្យរាជធានី ខេត្ត | ២៦០ ០០០ |
| ២១ | នាយករងសាលាមធ្យមសិក្សាគរុកោសល្យ មត្តេយ្យមជ្ឈឹម | ២៦០ ០០០ |
| ២២ | នាយករងវិទ្យាល័យ | ២៧០ ០០០ |
| ២៣ | នាយករងមជ្ឈមណ្ឌលបណ្ដុះបណ្ដាលគ្រូអប់រំកាយនិងកីឡា | ២៧០ ០០០ |
| ២៤ | នាយករងមជ្ឈមណ្ឌលគរុកោសល្យភូមិភាគ | ២៧០ ០០០ |
| ២៥ | គ្រូឧទ្ទេសមធ្យមសិក្សាទុតិយភូមិ (ក្របខណ្ឌគ្រូបង្រៀនកម្រិតឧត្តម) | ២៧០ ០០០ |
| ២៦ | នាយកវិទ្យាល័យ | ២៨០ ០០០ |
| ២៧ | នាយកសាលាគរុកោសល្យរាជធានី ខេត្ត | ២៩០ ០០០ |
| ២៨ | នាយកសាលាមធ្យមសិក្សាគរុកោសល្យ មត្តេយ្យមជ្ឈឹម | ២៩០ ០០០ |
| ២៩ | នាយកមជ្ឈមណ្ឌលគរុកោសល្យភូមិភាគ | ៣០០ ០០០ |
| ៣០ | នាយកមជ្ឈមណ្ឌលបណ្ដុះបណ្ដាលគ្រូអប់រំកាយនិងកីឡា | ៣០០ ០០០ |
| ៣១ | គ្រូបង្រៀនកម្រិតឧត្តម(បង្រៀននៅគ្រឹះស្ថានឧត្តមសិក្សា) | ៣៥៧ ០០០ |

| | | |
|---|---|---|
| ៣២ | អនុប្រធានដេប៉ាតឺម៉ង់(គ្រប់គ្រងគ្រូឧត្តមសិក្សា) | ៣៦០ ០០០ |
| ៣៣ | គ្រូឧទ្ទេសឧត្តមសិក្សា (ក្របខណ្ឌគ្រូបង្រៀនកម្រិតឧត្តម) | ៣៧០ ០០០ |
| ៣៤ | ប្រធានដេប៉ាតឺម៉ង់(គ្រប់គ្រងគ្រូឧត្តមសិក្សា) | ៣៧០ ០០០ |
| ៣៥ | អធិការមធ្យមសិក្សា | ៣៧០ ០០០ |
| ៣៦ | អធិការរង | ៦១៥ ០០០ |
| ៣៧ | អធិការ | ៦២២ ០០០ |
| ៣៨ | អនុប្រធានមជ្ឈមណ្ឌល | ៦៣០ ០០០ |
| ៣៩ | នាយករងវិទ្យាស្ថាន | ៦៣០ ០០០ |
| ៤០ | នាយកវិទ្យាស្ថាន | ៦៤០ ០០០ |
| ៤១ | ប្រធានមជ្ឈមណ្ឌល | ៦៤០ ០០០ |
| ៤២ | ព្រឹទ្ធបុរសរងមហាវិទ្យាល័យ | ៦៧០ ០០០ |
| ៤៣ | ប្រធានមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត | ៧០៣ ០០០ |
| ៤៤ | អនុប្រធាននាយកដ្ឋាន | ៧១៨ ០០០ |
| ៤៥ | ព្រឹទ្ធបុរសមហាវិទ្យាល័យ | ៧៦៣ ០០០ |
| ៤៦ | ប្រធាននាយកដ្ឋាន | ៧៨១ ០០០ |
| ៤៧ | អគ្គាធិការរង | ៧៩០ ០០០ |
| ៤៨ | សាកលវិទ្យាធិការរង | ៧៩០ ០០០ |
| ៤៩ | អគ្គនាយករង | ៧៩០ ០០០ |
| ៥០ | សាកលវិទ្យាធិការ | ៨២០ ០០០ |
| ៥១ | អគ្គាធិការ | ៨២០ ០០០ |
| ៥២ | អគ្គនាយក | ៨២០ ០០០ |

**មាត្រា៥ ៈ**

មន្ត្រីរាជការស៊ីវិលនៃក្របខណ្ឌគ្រូបង្រៀនកម្រិតបឋម ក្របខណ្ឌគ្រូបង្រៀនកម្រិតមូលដ្ឋាន និងក្របខណ្ឌគ្រូបង្រៀនកម្រិតឧត្តម កំពុងបម្រើការងារក្នុងក្រសួងអប់រំ យុវជន និងកីឡា ដែលត្រូវបានតែងតាំងឱ្យកាន់មុខតំណែងណាមួយក្នុងរចនាសម្ព័ន្ធនៃក្រសួងអប់រំ យុវជន និងកីឡា ត្រូវទទួលបានប្រាក់បំណាច់មុខងារផ្អែកលើប្រភេទក្របខណ្ឌ ប្រសិនបើប្រាក់បំណាច់មុខងារនៃមុខតំណែងនោះមានកម្រិតទាបជាង។

**មាត្រា៦ ៈ**

ប្រាក់បំណាច់មុខងាររដ្ឋបាល ជាប្រាក់បំណាច់មុខងារប្រចាំខែដែលត្រូវផ្តល់ជូនមន្ត្រីរាជការស៊ីវិលនៃក្របខណ្ឌភ្នាក់ងាររដ្ឋបាល ក្របខណ្ឌលេខាធិការរដ្ឋបាល ក្របខណ្ឌមន្ត្រីក្រមការ និងក្របខណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល កំពុងបំពេញមុខងារក្នុងមុខតំណែងនៅក្នុងរចនាសម្ព័ន្ធរបស់ក្រសួងអប់រំ យុវជន និងកីឡា ដូចមានកំណត់ក្នុងតារាងខាងក្រោម៖

| ល.រ | បរិយាយ | ប្រាក់បំណាច់មុខងាររដ្ឋបាល (រៀល) |
|---|---|---|
| ១ | ភ្នាក់ងាររដ្ឋបាល | ១០៥ ០០០ |
| ២ | លេខាធិការរដ្ឋបាល | ១០៥ ០០០ |
| ៣ | មន្ត្រីក្រមការ | ១២៦ ០០០ |
| ៤ | មន្ត្រីគ្រប់គ្រងរដ្ឋបាល | ១៦៤ ០០០ |

**មាត្រា៧ ..**

ប្រាក់បំណាច់មុខងារដែលបានកំណត់ក្នុងអនុក្រឹត្យនេះ ត្រូវអនុវត្តចាប់ពីថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០១៤ នេះតទៅ។

**មាត្រា៨ ..**

បទបញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍។

**មាត្រា៩ ..**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៨ ខែ កញ្ញា ឆ្នាំ២០១៤

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រីសូមហត្ថលេខា

**រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ និងជា**

**ប្រធានគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ**

**ពេជ្រ ប៊ុនធិន**

**កន្លែងទទួល ៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៩
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ